# ប្រាសាទស្រែប្រាសាទ

ប្រាសាទស្រែប្រាសាទ មានទីតាំងស្ថិតនៅភូមិស្រែវាល ឃុំដងកាំបិត ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ចម្ងាយប្រមាណ ១០០គីឡូម៉ែត្រពីទីរួមខេត្ត និងស្ថិតនៅកៀកតំបន់ព្រៃឡង់។ នៅសម័យអាណានិគមបារាំង ប្រាសាទនេះពុំធ្លាប់មានអ្នកស្រាវជ្រាវណាមកសិក្សាឡើយ ពោល គឺទើបតែនៅសតវត្សរ៍ទី២១នេះ ដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយសាលាបារាំងចុងបូព៌ាប្រទេស មកសិក្សានិងចុះបញ្ជី។

ប្រាសាទនេះសាងអំពីឥដ្ឋ មានរាងបួនជ្រុងស្មើ មានយ៉លយបន្តិច បែរមុខទៅទិសខាងកើត ហើយខាងកើតមានស្រះធំមួយ។ តួប៉មនេះមានប្រវែង ៤,៩០ម៉ែត្រ យ៉លយទៅទិសខាងកើតមានប្រវែង ១ម៉ែត្រ ហើយមានកម្ពស់សរុប ៧ម៉ែត្រ។ ឥដ្ឋរបស់ប្រាសាទមានប្រវែងជាមធ្យមបណ្ដោយ ៣០ស.ម. ទទឹង ១៣ស.ម. និងកម្រាស់ ៦ស.ម.។ សព្វថ្ងៃ នៅខាងក្នុងប្រាសាទបានក្លាយជាប្រហោងជ្រៅមួយ កើតចេញពីការជីកបំផ្លាញរុករកវត្ថុបុរាណដោយជនខិលខូចជាច្រើនលើកច្រើនសារ។ ចំណែក ជញ្ជាំងរបស់ប្រាសាទនៅទិសខាងលិច ខាងជើង និងខាងត្បូង យើងមើលលែងយល់ទៅហើយ ដោយសារបំណែកឥដ្ឋដែលធ្លាក់មកពីកំពូលប្រាសាទមកកប់បាត់ជញ្ជាំង។ ប៉ុន្តែ ផ្នែកខ្លះដែលនៅសល់អាចឱ្យយើងដឹងថា ប្រាសាទនេះពុំមានទ្វារបញ្ឆោតដូចប្រាសាទដទៃទៀតទេ តែគេធ្វើជញ្ជាំងឥដ្ឋលាត ឬអាចមានលម្អត្រឹមតែសសរផ្អោបដែលនៅជាប់ជញ្ជាំង ដូចប្រាសាទមួយចំនួនក្នុងក្រុមប្រាសាទសំបូរព្រៃគុក តួប៉ម N9, N10។

ក្បាច់លម្អរបស់ប្រាសាទពុំមាននៅសេសសល់ច្រើននោះទេ លើកលែងតែផ្ដែរទ្វារមួយធ្វើអំពីថ្មភក់ ដែលយើងឃើញធ្លាក់នៅខាងមុខប្រាសាទ។ ផ្ដែរទ្វារនេះមានបណ្ដោយ ១៤៩ស.ម. ទទឹង ៩៥ស.ម. កម្រាស់ ៣០ស.ម. ដែលមានលម្អដោយរូបសត្វមករបែរមុខចូលក្នុងខ្នាក់ឬលេបក្បាច់បន្ទាត់ធ្នូ។ ក្រៅពីរូបសត្វមករ យើងអាចនៅមើលឃើញតែរំយោលផ្កាតិចតួចទៀតប៉ុណ្ណោះ ដោយហេតុថាក្បាច់នៅលើផ្ដែរបានរលុបស្ទើរពេញមួយផ្ទៃផ្ដែរទៅហើយ។ ទោះបីជាយ៉ាងណា យើងអាចដឹងថា ផ្ដែរនេះមានលំនាំដូចផ្ដែរជាច្រើនទៀតដែលរកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុក ដែលជាសិល្បៈរចនាបថសំបូរព្រៃគុក សតវត្សរ៍ទី៧ ហើយប្រាសាទនេះអាចសាងនៅក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦ ដល់ ៦៣៧)។

តាមរយៈតឹកតាងនេះ យើងអាចសន្និដ្ឋានបានថា ទីតាំងប្រាសាទស្រែប្រាសាទ អាចជាតំបន់មួយដែលមានមនុស្សតាំងទីរស់នៅនាសម័យចេនឡា ហើយក៏អាចមានទំនាក់ទំនងទៅមក

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ឥតដាច់ជាមួយសហគមន៍មនុស្សនៅរាជធានីឦសានបុរ ដ្បិតបើមើលតាមភូមិសាស្ត្រ គឺនៅមិនឆ្ងាយពីគ្នាប៉ុន្មានទេ។

អត្ថបទដោយះ ម៉ន់ រ៉ាលី



រូបទី១ៈ ប្រាសាទស្រែប្រាសាទ (មើលពីទិសខាងត្បូង)



រូបទី២ៈ ប្រាសាទស្រែប្រាសាទ (មើលពីទិសឦសាន)

អត្ថបទដោយៈ ម៉ង់ វ៉ាលី



រូបទី៣៖ ខ្លោងទ្វារប្រាសាទស្រែប្រាសាទ



រូបទី៤៖ ផ្តែរទ្វារប្រាសាទស្រែប្រាសាទ

អត្ថបទដោយៈ ម៉ង់ វ៉ាលី